**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ០៤៦ សណ ១៧ អអក

ភ្នំពេញ, ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្ដីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្ដីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ លោកស្រី ឃុន ណៃហៀក សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកស្ទោង និងស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ

អាជ្ញាធរអគ្គិសនីកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងស្រុកស្ទោង និងស្រុកប្រសាទបល្ល័ង្គ ខេត្តកំពង់ធំ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណរួម (ផលិតកម្ម និងចែកចាយ) ឲ្យលោកស្រី ឃុន ណៃហៀក សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកស្ទោង និងស្រុកប្រសាទបល្ល័ង្គ ខេត្តកំពង់ធំ ។ ពេលនេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានអនុញ្ញាតឲ្យលោកស្រី ឃុន ណៃហៀក ទិញអគ្គិសនីពីក្រុហ៊ុន ប៊ីវីស៊ី ផៅវ័រ ឌីវេឡុបមេន មកជំនួសឲ្យការផលិតដោយម៉ាស៊ីនផ្ទាល់ខ្លួន ។ ដោយឃើញថា នៅតំបន់ធ្វើសេវាកម្មរបស់ស្រី ឃុន ណៃហៀក លែងត្រូវការមធ្យោបាយផលិតកម្មទៀតហើយ ដូច្នេះអាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់លោកស្រី ឃុន ណៃហៀក ដោយប្ដូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម មកអាជ្ញាបណ្ណចែកចាយវិញ តាមខ្លឹមសារដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជន មានសិទ្ធិពិនិត្យផ្ដល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្ដីព្រាងសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដែលគ្រោងផ្ដល់ជូនលោកស្រី ឃុន ណៃហៀក ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្ដីព្រាងសេចក្ដីសម្រេចនៅ.............................................. ..........................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងស្រុកស្ទោង និងស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្ដល់យោបល់លើខ្លឹមសារនៃការចេញសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោកស្រី ឃុន ណៃហៀក អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្ដល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា ចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ** " ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីមែល** : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្តីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី២
## លើឯកសារអាជ្ញាបណ្ណលេខ ៣៥៤ ឯអ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ សម្រាប់លោកស្រី ឃុន ណៃហៀក ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុកស្ទោង និងស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ

## សម្រាប់ការប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម មកអាជ្ញាបណ្ណចែកចាយ

**DECISION ON THE SECOND REVISION**

TO THE LICENSE DOCUMENT No.354 LD DATED APRIL 23, 2013 OF MRS. KHUN NAYHEAK FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF STOUNG AND PRASAT BALAING DISTRICTS, KAMPONG THOM PROVINCE

**FOR CHANGING THE TYPE OF LICENSE**

**FROM CONSOLIDATED LICENSE TO DISTRIBUTION LICENSE**

ថ្ងៃទី      ខែ      ឆ្នាំ២០១៧

., 2017